**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សារលិខិតជូនពរ

**សូមគោរពជូន**
**សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវឌ្ឍ គង់ សំអុល**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**

**សម្តេចចៅហ្វាវាំង ជាទីគោរពដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសចម្រើនជន្មាយុរបស់ **សម្តេចចៅហ្វាវាំង** នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២នេះ យើងខ្ញុំ ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវការចូលរួមអបអរសាទរ និង គោរពជូនពរចំពោះ **សម្តេចចៅហ្វាវាំង** សូមសមប្រកបដោយសុខភាពល្អបរិបូរណ៍ ពលានុភាពខ្លាំងក្លា បញ្ញាញាណវាងវៃ និងមានជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការកោតសរសើរដោយស្មោះ អស់ពីដួងចិត្ត ជូនចំពោះ **សម្តេចចៅហ្វាវាំង** ដែលបានខិតខំបំពេញភារកិច្ចអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ជង្វែតាម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងការលះបង់គ្រប់បែបយ៉ាង បម្រើឧត្តម ប្រយោជន៍ជាតិ សាសនា ព្រះមហាក្សត្រ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមអនុញ្ញាតគោរព ជូនពរ **សម្តេចចៅហ្វាវាំង និងលោកជំទាវ** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមសម ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវឌ្ឍ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងព្រះបរមរាជវាំង** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ៤ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**